# ដំណឹងជ្រើសរើសបុគ្គលិក ស្ម័គ្រចិត្ត

## តួនាទី៖ បុគ្គលិក សម្របសម្រួលផ្នែកកសិកម្ម

អង្គការ អាយស៊ីស៊ី គឺជាអង្គការគ្រិស្តបរិស័ទដែលធ្វើការអភិវឌ្ឍគ្រប់ជ្រុងជ្រោយ ដើម្បីចូលរួម ជួយគាំទ្រអ្នកដែលត្រូវបានគេយកចិត្តទុកដាក់តិចតួច នៅក្នុងព្រះរាជាណាចក្រកម្ពុជា

គម្រោងកាត់បន្ថយភាពក្រីក្រតាមរយៈការធ្វើឲ្យប្រសើរឡើង នូវសុខមាលភាពគ្រួសារ សិក្សាធិការនៃអង្គការ អាយស៊ីស៊ី គឺជាគម្រោងអភិវឌ្ឍន៍មួយដែលធ្វើការជាមួយសហគមន៍ដែលត្រូវបានយកចិត្តទុកដាក់តិចតួច គឺគ្រួសារក្រីក្រ និងក្រខ្លាំង និង សាលារៀន នៅស្រុកកំពង់រោទិ៍ និងស្រុកចន្ទ្រា ខេត្តស្វាយរៀង។ ក្នុងគោលបំណង ពង្រឹងស្មារតីឲ្យចេះផលិតស្បៀង និងប្រាក់ចំណូលឲ្យបានគ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ពួកគេ និងមានបទពិសោធន៍ធ្វើឲ្យគំនិតស្មារតីមានភាពប្រសើរឡើង និងសិស្សានុសិស្សទទួលបានការសិក្សាប្រកបដោយគុណភាព និងសមធម៌។ គម្រោងត្រូវការជ្រើសរើសបុគ្គលិកស្ម័គ្រចិត្តជនជាតិខ្មែរម្នាក់ ដើម្បីបំពេញមុខតំណែងខាងក្រោម

**បុគ្គលិក សម្របសម្រួល ផ្នែកកសិកម្ម** ( **ស្ម័គ្រចិត្ត** ) ប្រចាំការិយាល័យគម្រោង អភិវឌ្ឍន៍គ្រួសារ និងសាលារៀន (FAST)ប្រចាំខេត្តស្វាយរៀង។

**បរិយាយពីតួនាទី៖**

1. ចុះសួរសុខទុក្ខគ្រួសារកសិករ ឲ្យពួកគាត់មានការចូលរួមនៅក្នុងសកម្មភាពគម្រោង និងប្រមូលព័ត៌មានសំរាប់ការសរសេររបាយការណ៍
2. ជំនួយការដល់ប្រធានផ្នែកកសិកម្មនៅក្នុងការរៀបចំមេរៀន និងឯកសារសម្រាប់កសិករ
3. ធ្វើការសម្របសម្រួល ក្នុងការជ្រើរើសកសិករគំរូ ហើយដឹកនាំប្រជុំឆ្លុះបញ្ចាំង និងរៀនសូត្រ
4. តាមដានសកម្មភាពគម្រោងដែលបានអនុវត្ត ជាពិសេសគ្រួសារក្រីក្រ ឲ្យមានឱកាសក្នុងការទទួលនិងអនុវត្តសកម្មភាពគម្រោង
5. ចែករំលែកចំណេះដឹង បច្ចេកទេសកសិកម្ម ដល់កសិករ ឲ្យអនុវត្តជាសកម្មភាពបង្កើនប្រាក់ចំណូល និងធ្វើការតាមដានជាទៀងទាត់
6. ធ្វើការកត់ត្រា និងវិភាគនូវព័ត៌មាននៅតាមសហគមន៍ ហើយឆ្លុះបញ្ចាំងក្នុងការស្វែងរកគន្លឹះដើម្បី ឲ្យការអនុវត្តសកម្មភាពប្រកបដោយប្រសិទ្ធិភាព
7. រៀបទិន្នន័យកសិករ និងចូលរួមប្រជុំនៅក្នុងគម្រោង
8. កសាងទំនាក់ទំនងល្អជាមួយ បុគ្គលិក FAST អាជ្ញាធរ និង អង្គការដៃគូនានា
9. ទទួលការងារ ផ្សេងទៀត នៅពេលប្រធានផ្នែក ឬ ប្រធានគម្រោងស្នើសុំអោយជួយ

**លក្ខណៈសម្បត្តិ**

- បញ្ចប់ការសិក្សា ឬកំពុងរៀននៅសាលា លើមុខវិជ្ជាកសិកម្ម
- ចេះធ្វើការងារជាក្រុម

- ជាមនុស្សមានចរិតចាស់ទុំ ថ្លៃថ្នូរ ស្មោះត្រង់ និងមានសីលធម៌ល្អ
- ជាមនុស្សមានសមត្ថភាព និងមានឆន្ទះក្នុងការរៀនសូត្រ
- ចេះនិយាយ ស្តាប់ និងសរសេរភាសាខ្មែរល្អ និង បើចេះភាសាអង់គ្លេសបានល្អកាន់តែប្រសើរ
- មានជំនាញកុំព្យូទ័រល្អ លើកម្មវិធី Word, Excel
- មានសមត្ថភាព និងឆន្ទះគោរពតាម និងអនុវត្តគុណតម្លៃដែលអាយស៊ីស៊ីជាអង្គការគ្រិស្តបរិស័ទ

**ការដាក់ពាក្យ**

បេក្ខជនដែលចាប់អារម្មណ៍ត្រូវបំពេញនូវពាក្យស្នើសុំជាមួយនឹងព័ត៌មានទំនាក់ទំនង និងប្រវត្តិរូប ឲ្យបានមុនថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨។ ពាក្យស្នើសុំនេះត្រូវដាក់មកការិយាល័យ អង្គការ អាយស៊ីស៊ី គម្រោងអភិវឌ្ឍន៍គ្រួសារ និងសាលារៀន (FAST) ស្ថិតនៅភូមិស្រះវង់ សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង។

ទំនាក់ទំនង៖ ទូរសព្ទ ០១២ ២៦១ ៥០៧, ០៩២ ១៤៨ ០៤០ អ៊ីម៉ែល fast_pm@icc.org.kh ឬ នៅការិយាល័យកណ្តាលស្ថិតនៅផ្ទះលេខ ៧B1 ផ្លូវសរទ្បា 371 ភូមិអ័រគីដេ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ទំនាក់ទំនង៖ ទូរសព្ទ ០៩២ ៥៣២ ៥៦២។

ទម្រង់ស្នើសុំ អាចទាញយកពីគេហទំព័ររបស់អង្គការអាយស៊ីស៊ី៖

http://www.icc.org.kh/opportunities.php ចំពោះការស្នើសុំនោះ នឹងមិនទទួលឡើយ ក្នុងករណីគ្មានការបំពេញពាក្យស្នើសុំ។ មានតែបេក្ខជនដែលត្រូវសម្ភាសន៍ប៉ុណ្ណោះ ដែលនឹងទំនាក់ទំនង។ បេក្ខជនទទួលបានជោគជ័យគឺតម្រូវឲ្យគោរពតាមក្បួនច្បាប់បុគ្គលិកជាតិរបស់ អង្គការអាយស៊ីស៊ី ហើយនឹងគោលនយោបាយផ្សេងៗទៀត ទៅ៕